# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តប៉ៃលិន**

**គណៈកម្មាធិការលទ្ធកម្ម**

**លេខ:..................**

**បានពិនិត្យត្រឹមត្រូវ**

**អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**

# សេចក្ដីជូនដំណឹង

## ស្ដីពីការអញ្ជើញចូលរួមដេញថ្លៃ

## ស្ដីពីការងារសាងសង់អគាររដ្ឋបាលសាលាខេត្តប៉ៃលិនថ្មីបន្ត ( ជំហានទី២ )

## មានទំហំ ( ៤២ម x ៣៣ម ) មានកំពស់បួនជាន់ ដំបូលប្រក់គ្រឿង ស្ថិតក្នុងបរិវេណសាលាខេត្ត

## ជូនសាលាខេត្តប៉ៃលិន សម្រាប់ឆ្នាំ២០១៧

ខេត្តប៉ៃលិន សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថាៈ **ខេត្តប៉ៃលិន** នឹងដាក់អោយដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារសាងសង់អគាររដ្ឋបាលសាលាខេត្តប៉ៃលិនថ្មីបន្ត ( ជំហានទី២ ) មានទំហំ ( ៤២ម x ៣៣ម ) មានកំពស់បួនជាន់ ដំបូលប្រក់គ្រឿង ស្ថិតក្នុងបរិវេណសាលាខេត្ត ជូនសាលាខេត្តប៉ៃលិន **សម្រាប់ឆ្នាំ២០១៧** ។

ខេត្តប៉ៃលិន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ ។ឯកសារដេញថ្លៃ មានដាក់លក់នៅ **អង្គភាពលទ្ធកម្មខេត្តប៉ៃលិន** អាសយដ្ឋាន នៅសាលាខេត្តប៉ៃលិន ចាប់ពីថ្ងៃទី...១៤....ខែ.កក្កដា...ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ ទូរស័ព្ទទាក់ទងលេខ: ០៧៧ ៨៦ ៩៨៨៦ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនមក **អង្គភាពលទ្ធកម្ម** យ៉ាងយូរបំផុតត្រឹមថ្ងៃទី...២៤.....ខែ.កញ្ញា... ឆ្នាំ២០១៧ វេលាម៉ោង ១៤:០០.... នាទី ។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅ **អង្គភាពលទ្ធកម្ម** តាមអាសយដ្ឋានខាងលើ វេលាម៉ោង ..១៤:០០.... នាទី ថ្ងៃទី..២៤....ខែ.កញ្ញា....ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយ **អង្គភាពលទ្ធកម្ម** ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ខេត្តប៉ៃលិន ថ្ងៃទី...០៥......ខែ..កក្កដា.....ឆ្នាំ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អៀង ភុង**

**<u>ចម្លងជូន</u>**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ